# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

# គណបក្ស ភ្លើងទៀន

សីលធម៌ សច្ចធម៌ យុត្តិធម៌

**កម្មវិធីនយោបាយគណបក្ស ភ្លើងទៀន**

**២០២៣**

# មាតិកា

ទំព័រ

ប្រវត្តិគណបក្សភ្លើងទៀន------------------ ១

សេចក្តីប្រកាស------------------------------- ៣

១. ចក្ខុវិស័យ -------------------------------- ៥

២. បេសកកម្ម ------------------------------- ៦

៣. គោលដៅ -------------------------------- ៧

៤.បាវចនា និងរូបសញ្ញា------------------- ៨

៥. មាគ៌ានយោបាយក្នុងប្រទេស---------- ៩

៦. មាគ៌ានយោបាយក្រៅប្រទេស---------១២

៧. កម្មវិធីនយោបាយអាទិភាព ----------១៥

# ប្រវត្តិគណបក្ស ភ្លើងទៀន

ក្រោយការចាប់បដិសន្ធិនៃកិច្ចព្រមព្រៀងសន្តិភាព ទីក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ បណ្តាប្រទេសជាមិត្តបានចាប់ផ្តើមជំរុញឱ្យមានសន្តិភាព និងលទ្ធិប្រជាធិបតេយ្យនៅប្រទេសកម្ពុជា និងបានរៀបចំនូវការបោះឆ្នោតដោយសេរីត្រឹមត្រូវមួយ នៅខែឧសភា ឆ្នាំ១៩៩៣ ក្រោមការត្រួតពិនិត្យរបស់អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំកម្ពុជា ហៅកាត់ថា អ៊ុនតាក់ (UNTAC) ដែលបានផ្តល់ជ័យជម្នះ ឱ្យកម្លាំងអ្នកស្នេហាជាតិ និងប្រជាធិបតេយ្យ។ លទ្ធផលនៃការបោះឆ្នោតនោះសឲ្យឃើញថា ប្រជារាស្ត្រខ្មែរចង់ ឱ្យមានការផ្លាស់ប្តូររបបនយោបាយគ្រប់គ្រងប្រទេស និងរបៀបរៀបចំសង្គមជាតិឱ្យទទួលបាននូវការរីចម្រើន ប្រកបដោយចីរភាព សេរីភាព និងយុត្តិធម៌ ព្រមទាំងទទួលបានឡើងវិញនូវ

ឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពទឹកដីពេញលេញ។ ប៉ុន្តែអ្វីដែលជាក្តីសង្ឃឹម នៃប្រជារាស្ត្រខ្មែរនៅពេលនោះ មិនទាន់បានសម្រេច ដោយសារបញ្ហាជាតិធំៗ ដូចជាអំពើពុករលួយ ភាពក្រីក្រ អយុត្តិធម៌សង្គម ការកាប់បំផ្លាញព្រៃឈើ ការរំលោភសិទ្ធិមនុស្ស បូរណភាពទឹកដី អន្តោប្រវេសន៍ខុសច្បាប់ មិនទាន់ត្រូវបានដោះស្រាយទាំងស្រុងនៅឡើយ។

នៅក្នុងកាលៈទេសៈនោះហើយ ដែល**គណបក្សជាតិខ្មែរ** ត្រូវបានបង្កើតឡើងនៅថ្ងៃទី០២ ខែវិច្ឆិកា ហើយដែលត្រូវបានប្រកាសជាផ្លូវការ នៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ដើម្បីប្រមូលផ្តុំកម្លាំងអ្នកស្នេហាជាតិ និងប្រជាធិបតេយ្យ ដែលចង់កសាង និងរៀបចំប្រទេសឡើងវិញឱ្យបានល្អត្រឹមត្រូវ ផ្អែកលើគោលការណ៍ **សីលធម៌ សច្ចធម៌ និងយុត្តិធម៌**។

នៅថ្ងៃទី១០ ខែមីនា ១៩៩៨ **គណបក្សជាតិខ្មែរ** បានប្រារព្ធធ្វើសមាជវិសាមញ្ញមួយ ដោយត្រូវបង្ខំចិត្តប្តូរឈ្មោះ **គណបក្សជាតិខ្មែរ** ទៅជា **គណបក្ស សម រង្ស៊ី** ដោយយកតាមឈ្មោះលោកប្រធានស្ថាបនិក **សម រង្ស៊ី** ដើម្បីធានាមិនឱ្យមានការលួច ឬបន្លំយកឈ្មោះគណបក្សទៅបម្រើឱ្យជនខិលខូច។ គណបក្សក៏បានកំណត់យករូប "**ទៀនមានពន្លឺ**" ជាសញ្ញាសម្គាល់ផងដែរ។

នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៨ **គណបក្ស សម រង្ស៊ី** បានចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រសម្រាប់អាណត្តិទី២ តែដោយការបោះឆ្នោតនៅពេលនោះ មិនបានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ធ្វើឱ្យគណបក្ស សម រង្ស៊ី ទទួលបានអាសនៈតំណាងរាស្ត្រតែ ១៥ ប៉ុណ្ណោះនៅក្នុងរដ្ឋសភា។ **គណបក្ស សម រង្ស៊ី** បានក្លាយទៅជា

គណបក្សជំទាស់តែមួយគត់ ដើម្បីប្រកួតប្រជែងក្នុងការកសាងប្រទេសឱ្យបានល្អ ត្រឹមត្រូវ និងជាតំណាងឆន្ទៈពិតប្រាកដ របស់ប្រជារាស្ត្រខ្មែរ ដែលជាក្តីសង្ឃឹមតែមួយគត់របស់ប្រជារាស្ត្រក្នុងការការពារផលប្រយោជន៍ជាតិ ជំរុញឱ្យលទ្ធិប្រជាធិបតេយ្យរីកចម្រើន ការគោរពសិទ្ធិមនុស្ស លើកស្ទួយជីវភាពប្រជាពលរដ្ឋ និងលើកតម្កើងយុត្តិធម៌ សង្គម ព្រមទាំងការពារឯករាជ្យភាពជាតិ និងបូរណភាព ទឹកដីឱ្យបានគង់វង្ស។

នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៧ **គណបក្ស សម រង្ស៊ី** បានប្រារព្ធសមាជវិសាមញ្ញមួយ ហើយបានសម្រេចប្តូរឈ្មោះ **គណបក្ស សម រង្ស៊ី** ទៅជា "គណបក្ស ភ្លើងទៀន" ដើម្បីឱ្យស្របតាមច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ដោយគណបក្សបានកំណត់រក្សារូប **"ទៀនមានពន្លឺ"** ជា

សញ្ញាសម្គាល់ និងមានបាវចនា "**សីលធម៌ សច្ចធម៌ យុត្តិធម៌**" ដដែល។

# សេចក្តីប្រកាស

**គណបក្ស ភ្លើងទៀន** យកចិត្តទុកដាក់ជាចម្បងលើការពង្រឹងឯកភាពជាតិ និងការបង្រួបបង្រួមជាតិខ្មែរទាំងមូល តាមរយៈការគោរពសិទ្ធិមនុស្សឲ្យបានត្រឹមត្រូវ ការអនុវត្តលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ការពង្រឹងនីតិរដ្ឋ ជាមួយការលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខ្មែរ ជាពិសេស កសិករ ស្ត្រី ប្រជាពលរដ្ឋក្រីក្រគ្មានដីធ្លី រួមទាំងការអប់រំ និងការងារត្រឹមត្រូវសម្រាប់យុវជន។

**គណបក្ស ភ្លើងទៀន** ប្ដេជ្ញាការពារឯករាជ្យ បូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ឲ្យនៅគង់វង្ស និងរួមរស់ដោយសន្តិភាព ជាមួយប្រទេសជិតខាង។

រាជរដ្ឋាភិបាលថ្មីដឹកនាំដោយ**គណបក្ស ភ្លើងទៀន** នឹងចាត់វិធានការជាបន្ទាន់ដូចខាងក្រោម៖

-លុបបំបាត់អំពើពុករលួយ ដែលជាមូលដ្ឋាននាំឲ្យមានអយុត្តិធម៌សង្គម និងភាពក្រីក្រ។

-ពង្រឹងការអនុវត្តច្បាប់ និងការកសាងប្រទេសឲ្យមាននីតិរដ្ឋពិតប្រាកដ តាមរយៈតុលាការឯករាជ្យស្អាតស្អំ ការអនុវត្តលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្សការគោរពសិទ្ធិមនុស្ស និងយុត្តិធម៌សង្គម ដើម្បីធានាសន្តិភាពអចិន្ត្រៃយ៍។

-លើកកម្ពស់ជីវភាពប្រជាពលរដ្ឋខ្មែរតាមរយៈការអនុវត្ត **សារនយោបាយអាទិភាព ៥ ចំណុច** ដូចតទៅ៖

១-ការអប់រំល្អ បង្កើតការងារសម្រាប់យុវជន ១លាននាក់

២-កម្មករ ប្រាក់ខែទាបបំផុត ១លាន ២សែនរៀល និងមន្រ្តីរាជការ ទាបបំផុត ២លានរៀល

៣-កសិផលថ្លៃ ជីថោក ប្រេងថោក ការប្រាក់ទាប

៤-ចាស់ៗអាយុ ៦៥ឡើង ទទួលបានប្រាក់ ២០ម៉ឺនរៀល រៀងរាល់ខែ

៥-ពិនិត្យ ព្យាបាលជម្ងឺ នៅមន្ទីរពេទ្យរដ្ឋ ឥតបង់ប្រាក់

# គណបក្ស ភ្លើងទៀន

## (រាជរដ្ឋាភិបាលរបស់ខ្មែរទាំងអស់គ្នា)

### ១-<u>ចក្ខុវិស័យ</u>

***គណបក្ស ភ្លើងទៀន*** *នឹងកសាងប្រទេសជាតិ ឲ្យក្លាយជាប្រទេសមួយដែលមានឯករាជ្យភាព បូរណភាពអធិបតេយ្យជាតិពេញលេញ និងដែលប្រជាពលរដ្ឋខ្មែរគ្រប់ៗរូបមានឱកាសស្មើគ្នា ដើម្បីកសាងអនាគតរបស់ខ្លួន ឲ្យបានថ្លៃថ្នូរសម្បូរសប្បាយ។*

### ២-បេសកកម្ម

**គណបក្ស ភ្លើងទៀន** មានបេសកកម្ម ប្រឆាំងរាល់ការឈ្លានពានពីបរទេស ប្រឆាំងការគ្រប់គ្រងផ្តាច់ការ

ប្រឆាំងអំពើពុករលួយ និងអំពើអយុត្តិធម៌គ្រប់បែបយ៉ាង ដើម្បីជួយប្រទេសជាតិឲ្យរួចខ្លួនផុតពីគ្រោះមហន្តរាយទាំងឡាយ ហើយរៀបចំពង្រឹងស្ថាប័នជាតិ ឲ្យមានប្រសិទ្ធភាពក្នុងការផ្តល់សេវាបម្រើប្រជាពលរដ្ឋគ្រប់រូប ឲ្យបានល្អត្រឹមត្រូវ។

## ៣-គោលដៅ

**គណបក្ស ភ្លើងទៀន** មានគោលដៅប្រមូលផ្តុំកម្លាំងអ្នកស្នេហាជាតិ អ្នកស្រឡាញ់លទ្ធិប្រជាធិបតេយ្យគ្រប់និន្នាការ ទាំងក្នុង និងក្រៅប្រទេស ដើម្បីរួបរួមគ្នាលើកតម្កើងការអនុវត្តលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស តាមរយៈការបោះឆ្នោតដោយសេរីត្រឹមត្រូវ និងយុត្តិធម៌ ដើម្បីធានានូវអំណាចប្រជាពលរដ្ឋ ក្នុងការជ្រើសរើសអ្នកដឹកនាំរបស់ខ្លួន សម្រាប់

គ្រប់គ្រងប្រទេសឲ្យបានរីកចម្រើន ប្រកបដោយការទទួលខុសត្រូវ ក្នុងសង្គមមួយដែលមាននីតិរដ្ឋ និងយុត្តិធម៌ ពិតប្រាកដ។

## ៤-បាវចនា

**គណបក្ស ភ្លើងទៀន** មានបាវចនា៖

**សីលធម៌ សច្ចធម៌ យុត្តិធម៌**

Morality Truth Justice

## ៥-រូបសញ្ញា

**គណបក្ស ភ្លើងទៀន** (Candlelight Party) មានរូប "**ទៀនមានពន្លឺ**" ជាសញ្ញាសម្គាល់។

"**ទៀនមានពន្លឺ**" តំណាងឲ្យ៖ **អនាគតរុងរឿង រួមគ្នាជាមហាគ្រួសារ និង សេចក្តីសង្ឃឹម**។

Bright Future, Unity of Candle and Hope.

## ៦-<u>មាគ៌ានយោបាយ</u>

### ក-<u>នយោបាយក្នុងប្រទេស</u>

**គណបក្ស ភ្លើងទៀន** មាននយោបាយដូចតទៅ ៖

១-រៀបចំឲ្យមានសន្តិភាពពិតប្រាកដ និងយូរអង្វែងជូនប្រទេសជាតិ តាមរយៈសង្គមដែលមានយុត្តិធម៌ និងការគោរពសិទ្ធិមនុស្សត្រឹមត្រូវ។

២-បំបាត់រាល់ការជួញដូរគ្រឿងញៀន អំពើហិង្សា និងអំពើអបាយមុខទាំងឡាយ ដើម្បីឲ្យមានសុវត្ថិភាពពេញលេញជូនប្រជាពលរដ្ឋ។

៣-ធានាការអនុវត្តលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សឲ្យបានត្រឹមត្រូវ ដោយមានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមួយ ដែលមានឯករាជ្យ តម្លាភាព និងមានសមត្ថភាព ក្នុងការរៀបចំការបោះឆ្នោត ប្រកបដោយសេរី ស្មើភាព និងយុត្តិធម៌ ព្រមទាំងស្ថាប័នជាតិដែលមានសមត្ថភាពបម្រើប្រជាពលរដ្ឋឲ្យបានល្អត្រឹមត្រូវ និងឯករាជ្យ។

៤-បំបាត់អំពើពុករលួយគ្រប់បែបយ៉ាង ជាពិសេសរៀបចំប្រព័ន្ធតុលាការឲ្យឯករាជ្យ មានភាពស្អាតស្អំ និងផ្តល់សេវាយុត្តិធម៌ត្រឹមត្រូវ ជូនប្រជាពលរដ្ឋដោយគ្មានការរើសអើង។

៥-អនុវត្តឲ្យបានត្រឹមត្រូវ នូវការគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញ នៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញា និងអនុសញ្ញាទាំងឡាយ ដែលទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី សិទ្ធិកុមារ សិទ្ធិជនពិការ និងសិទ្ធិជនជាតិដើម។ល។

៦-ដោះស្រាយបញ្ហាជនអន្តោប្រវេសន៍ខុសច្បាប់ ដោយអនុវត្តច្បាប់សញ្ជាតិ និងច្បាប់អន្តោប្រវេសន៍ ឲ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាព។

៧-ប្រកាន់យកគោលការណ៍យុត្តិធម៌សង្គម ដោយរដ្ឋត្រូវធានាឲ្យប្រជាពលរដ្ឋទទួលបាននូវសិទ្ធិសេរីភាពគ្រប់បែបយ៉ាង និងមានឱកាសស្មើគ្នាខាងនយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ច។

៨-ប្រកាន់យកគោលការណ៍ប្រជាធិបតេយ្យ សេរី ដោយគោរពប្រជាពលរដ្ឋជាម្ចាស់អំណាច ដែលក្នុងនោះប្រជាពលរដ្ឋម្នាក់ៗ មិនមែនត្រឹមតែមានសិទ្ធិចូលរួមក្នុងសកម្មភាពសង្គម ដើម្បីពង្រឹងភាពទទួលខុសត្រូវរបស់រដ្ឋាភិបាលប៉ុណ្ណោះទេ ប៉ុន្តែមានសិទ្ធិដកអំណាចពីអ្នកដឹកនាំរដ្ឋាភិបាលណា ដែលមិនបានបម្រើផលប្រយោជន៍ជាតិបានត្រឹមត្រូវពិតប្រាកដ។

៩-ប្រកាន់យកគោលការណ៍អភិវឌ្ឍន៍ប្រទេសប្រកបដោយនិរន្តរភាព ដែលជំរុញឲ្យមានការពង្រឹងការផលិតសម្រាប់នាំចេញប្រកបដោយភាពរឹងមាំ និងមានការប្រកួតប្រជែង ជាមួយការថែទាំធនធានធម្មជាតិ មានព្រៃឈើ មច្ឆជាតិ និងធនធានរ៉ែទាំងឡាយឲ្យបានគង់វង្សសម្រាប់ជាផលប្រយោជន៍ជាតិយូរអង្វែងតទៅ។

## ខ-នយោបាយក្រៅប្រទេស

**(១)-គណបក្ស ភ្លើងទៀន** អនុវត្តនយោបាយការបរទេស ដោយអនុលោមតាមរដ្ឋធម្មនុញ្ញដែលកំណត់ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹត្យ អចិន្ត្រៃយ៍ មិនចូលបក្សសម្ព័ន្ធ ដោយអនុវត្តគោលការណ៍ដែលមានជាអាទិ៍៖

-ការគោរពទៅវិញទៅមក នូវបូរណភាពទឹកដី និង អធិបតេយ្យភាព នៃប្រទេសជិតខាង ដោយមិនធ្វើសកម្មភាពបំពាបំពានលើលំហដែនដីរបស់ប្រទេសដទៃ។

-រស់នៅដោយសន្តិភាពជាមួយប្រទេសជិតខាង ដោយមិនគំរាមកំហែង មិនបង្កជម្លោះយោធាជាមួយប្រទេសណាមួយ។

-មិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងប្រទេសណាមួយ ដោយគោរពលើឆន្ទៈពលរដ្ឋប្រទេសនោះ ក្នុងការសម្រេចចិត្តដោយសេរី នូវរបបនយោបាយ និងមេដឹកនាំប្រទេសជាតិរបស់ខ្លួន។

-ពង្រឹងរាល់ការទំនាក់ទំនងខាងសេដ្ឋកិច្ច ពាណិជ្ជកម្ម រវាងប្រទេស និងប្រទេស ដោយឈរលើគោលការណ៍ផលប្រយោជន៍ស្មើភាពទៅវិញទៅមក។

(២)-**ដោះស្រាយបញ្ហាព្រំដែន** ដោយអនុលោមតាមសន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ ១៩៩១ និងប្រើប្រាស់សន្ធិសញ្ញា និងកិច្ចព្រមព្រៀងស្របច្បាប់ទាំងអស់ ដើម្បីធានាបូរណភាពទឹកដីខ្មែរទាំងមូល។

**(៣)**-ប្រឆាំងដាច់ខាតរាល់សកម្មភាពឈ្លានពានពីបណ្តាប្រទេសណាមួយដោយអំណាចទៅលើប្រទេស

ផិតខាងទន់ខ្សោយជាង ដោយបំពានដល់សិទ្ធិសម្រេចរបស់ពលរដ្ឋ ក្នុងការរស់នៅដោយឯករាជ្យ ក្នុងសេរីភាព និងតាមប្រពៃណីរបស់ខ្លួន។

**(៤)**-ចូលរួមយ៉ាងសកម្មជាមួយសហគមន៍អន្តរជាតិ ក្នុងការកាត់បន្ថយការឡើងកំដៅភពផែនដី ដោយរៀបចំជាផែនការយុទ្ធសាស្រ្ត និងសកម្មភាពថ្នាក់ជាតិដែលមានប្រសិទ្ធភាព។

(៥)-<u>រៀបចំស្ថានទូតខ្មែរនៅតាមប្រទេសនានា ដើម្បីជាតំណាងប្រជាជាតិខ្មែរទាំងមូល តែមិនតំណាងឲ្យគណបក្សនយោបាយ ដោយបម្រើសេវាដល់ពលរដ្ឋខ្មែរគ្រប់រូប ដោយមិនរើសអើង មិនពុករលួយ និងសេវាឆាប់រហ័ស។</u>

# **កម្មវិធីនយោបាយអាទិភាព**

# ៩ ចំណុច

*រាជរដ្ឋាភិបាលដឹកនាំដោយ* ***គណបក្ស ភ្លើងទៀន*** *គឺជា "**រាជរដ្ឋាភិបាលរបស់ខ្មែរទាំងអស់គ្នា**"។ ដើម្បីឆ្លើយតបទៅនឹងអត្ថន័យនេះ និងដើម្បីឲ្យស្របទៅនឹងបាវចនា* ***សីលធម៌ សច្ចធម៌ យុត្តិធម៌ គណបក្ស ភ្លើងទៀន*** *បានសម្រេចដាក់ចេញនូវកម្មវិធីនយោបាយជាអាទិភាព ដូចខាងក្រោម ៖*

## ១-ផ្នែកសេដ្ឋកិច្ច

**១.១.**ប្រកាន់យកគោលការណ៍ សេដ្ឋកិច្ចទីផ្សារសេរី ដែលមានការប្រកួតប្រជែងដោយសេរី និងស្មើភាពជាមួយការអភិវឌ្ឍប្រកបដោយសមធម៌ ដើម្បីលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ បង្កើតការងារ និងបង្កើនប្រាក់ចំណូល។

**១.២.**បង្កើនការផលិត ដើម្បីបម្រើសេចក្ដីត្រូវការក្នុងស្រុក និងនាំចេញទៅលក់នៅបរទេសដែលក្នុងនោះ មានជាអាទិ៍ ក្រសួងកសិកម្ម ក្រសួងឧស្សាហកម្ម និងក្រសួងពាណិជ្ជកម្ម ត្រូវសហការគ្នារៀបចំគំរោង និងសកម្មភាពជំរុញផែនការនេះ។

**១.៣.**ផ្ដល់សេវាឆាប់រហ័ស និងមានតម្លាភាព ដល់ការធ្វើពាណិជ្ជកម្មធុនតូច និងមធ្យម ហើយបង្កភាពងាយស្រួល និងការជឿទុកចិត្តដល់អ្នកវិនិយោគទុនត្រឹមត្រូវមកពីក្រៅប្រទេស។

## ១.៤.វិស័យឧស្សាហកម្ម និងសិប្បកម្ម

-លើកទឹកចិត្តដល់អ្នកវិនិយោគទុនក្នុង និងក្រៅប្រទេស លើការបង្កើតរោងចក្រ សហគ្រាស អាជីវកម្មនានា ដែលទិញយកផលិតផលកសិកម្មក្នុងស្រុក។

-បង្កើតមុខរបរសិប្បកម្ម ទៅតាមធនធានធម្មជាតិដែលមានតាមតំបន់ ដោយបង្កើតមណ្ឌលសិប្បកម្មក្នុងការផ្តល់ព័ត៌មានបច្ចេកទេស រកប្រភពដើមទុន និងទីផ្សារជូនដល់សិប្បករ។

### ១.៥.វិស័យពាណិជ្ជកម្ម

-ធ្វើឲ្យមានតុល្យភាពជញ្ជីងពាណិជ្ជកម្ម រវាងប្រទេសជិតខាង និងក្នុងតំបន់ តាមរយៈការបង្កើនការនាំចេញ។

-ជំរុញការរកស៊ីប្រកួតប្រជែង ដោយស្មើភាពឈរលើមូលដ្ឋានច្បាប់ និងតម្លាភាព។

-លើកទឹកចិត្តក្រុមហ៊ុនក្នុងប្រទេស និងក្រៅប្រទេសឲ្យដាក់ទុនវិនិយោគ ដើម្បីបង្កើនការផលិតសម្រាប់ការនាំចេញ បង្កើតការងារ និងប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក។

-រៀបចំបង្កើននិងលើកស្ទួយផលិតផលសម្រាប់សេចក្តីត្រូវការក្នុងស្រុក ដើម្បីទប់ស្កាត់ក្នុងការនាំចូល និងការការពារទីផ្សារ។

-បញ្ចូលក្រសួងពាណិជ្ជកម្ម ទៅក្នុងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ឲ្យទៅជាក្រសួងតែមួយ ដើម្បីប្រសិទ្ធភាព នៃការទាក់ទាញរកវិនិយោគទុនល្អៗ មកបណ្តាក់ទុននៅក្នុងស្រុក និងការរកទីផ្សារលក់ផលិតផលខ្មែរ។

## ១.៦.វិស័យទេសចរណ៍

-រៀបចំសេវាដឹកជញ្ជូនឲ្យល្អមានសុវត្ថិភាពតាមផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស និងសេវាបម្រើភ្ញៀវឲ្យបានល្អ រួមទាំងផ្នែកផ្តល់ទិដ្ឋាការផង។

-រដ្ឋគ្រប់គ្រងដោយខ្លួនឯងលើប្រាង្គប្រាសាទបុរាណ ធ្វើការលក់សំបុត្រចូលទស្សនាតំបន់អង្គរដោយប្រើ ប្រព័ន្ធអនឡាញ(online) និងលុបបំបាត់ការលួចបំបាត់ ប្រាក់ចំណូលក្នុងវិស័យនេះ។ ចំពោះពលរដ្ឋខ្មែរទាំង អស់ ទោះជាខ្មែរលើ ខ្មែរក្រោម និងខ្មែរដែលមានគ្រួសារ ជាជនបរទេស មិនត្រូវឲ្យបង់ប្រាក់ក្នុងការទស្សនា ប្រាសាទទេ។

-លើកទឹកចិត្តឲ្យភ្ញៀវបរទេស ស្នាក់នៅបានយូរ ដោយបង្កើតរមណីយដ្ឋានច្រើនតាមខេត្ត។

-អភិវឌ្ឍន៍បន្ថែមលើតំបន់ទេសចរណ៍ធម្មជាតិ ដើម្បីពង្រឹងការថែទាំបរិស្ថាន និងជួយដល់ជីវភាព ប្រជាពលរដ្ឋនៅមូលដ្ឋាន។

-ជំរុញការផលិតវត្ថុអនុស្សាវរីយ៍ក្នុងស្រុក។

## ១.៧.វិស័យទូរគមនាគមន៍

-ជំរុញការផ្តល់សេវាទូរស័ព្ទ និងអ៊ិនធឺណេត (Internet) ឲ្យបានល្អ ក្នុងតម្លៃថោក ដោយជំរុញឲ្យមានការរកស៊ីប្រកួតតប្រជែងដោយស្មើភាព។

-ធានាការប្រើប្រាស់បច្ចេកទេសទូរគមនាគមន៍ដើម្បីទទួលបានព័ត៌មានដោយសេរី។

## ១.៨.វិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-លុបបំបាត់ការិយាធិបតេយ្យដ៏ស្មុគស្មាញ និងអំពើពុករលួយ។

-ជំរុញការប្រមូលពន្ធឲ្យមានប្រសិទ្ធភាព។

-ជំរុញការអនុវត្តច្រកចេញ-ចូលតែមួយ ឲ្យមានប្រសិទ្ធភាព។

-តម្រូវឲ្យមានការចាយវាយរូបិយវត្ថុជាតិជាផ្លូវការពោលគឺប្រាក់រៀល។

-ទប់ស្កាត់យ៉ាងម៉ឺងម៉ាត់ពីសកម្មភាពនៃការលាងលុយកខ្វក់។

-ប្រើប្រាស់យន្តការ និងបច្ចេកទេស ដែលមានប្រសិទ្ធភាពបំផុតក្នុងការប្រមូលថវិកាជាតិ។

-ផ្តល់លទ្ធភាពដល់កសិករ និងអ្នកប្រកបមុខជំនួញខ្នាតតូច ឲ្យទទួលបានការខ្ចីប្រាក់ ដែលមានអត្រាការប្រាក់ទាបបំផុត និងមិនយកពន្ធ សម្រាប់ការនាំចេញផលិតផលកសិកម្ម។

## ២- ផ្នែកអប់រំ និងយុវជន

### ចក្ខុវិស័យ

*ការអប់រំ គឺជាឧបករណ៍ប្រសើរបំផុត សម្រាប់ការអភិវឌ្ឍប្រទេសបានជោគជ័យ តាមរយៈការបណ្តុះបណ្តាលមនុស្សឲ្យមានសមត្ថភាព និងមានការទទួលខុសត្រូវលើការងារក្នុងសង្គម ដោយក្នុងនោះរដ្ឋត្រូវផ្តល់ឱកាសស្មើភាពគ្នាដល់ប្រជាពលរដ្ឋគ្រប់រូប ក្នុងការទទួលបានការអប់រំប្រកប ដោយគុណភាព។*

**២.១.រាជរដ្ឋាភិបាលដឹកនាំដោយ គណបក្សភ្លើងទៀន** នឹងធ្វើកំណែទម្រង់ប្រព័ន្ធអប់រំស៊ីជម្រៅឲ្យមានគុណភាព បង្កើតស្តង់ដារក្នុងការអប់រំ លើកស្ទួយវិស័យអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយចំណាយថវិកាជាតិលើសពី ២៥% (ម្ភៃប្រាំ) ភាគរយ នៃថវិកាជាតិលើវិស័យអប់រំ ដើម្បីឲ្យពលរដ្ឋខ្មែរ ពិសេសយុវជនមានចំណេះដឹង ជំនាញពិតប្រាកដ ជាមួយការទទួល

បានការងារធ្វើត្រឹមត្រូវ និងទទួលបានប្រាក់ចំណូលខ្ពស់។

**២.២.រាជរដ្ឋាភិបាលដឹកនាំដោយ គណបក្ស ភ្លើងទៀន** នឹងជួយឲ្យយុវជនទទួលបានចំណេះដឹង និងជំនាញ គ្រប់គ្នា។ ចំពោះយុវជនចង់បន្តការសិក្សានៅសាលាជំនាញបច្ចេកទេស រដ្ឋផ្តល់ជូននូវការបណ្តុះបណ្តាលចំណេះវិជ្ជាជីវៈ និងជំនាញគ្រប់គ្រាន់ទៅតាមតម្រូវការទីផ្សារការងារ ដើម្បីអាចយកទៅប្រកបមុខរបរចិញ្ចឹមជីវិត ដោយរដ្ឋធានាផ្តល់ជូននូវប្រាក់កម្ចីដែលមានការប្រាក់ទាប សម្រាប់ធ្វើដើមទុន និងមានការផ្តល់សេវាប្រឹក្សាយោបល់។

**២.៣.**ផ្តល់ជំនួយថវិកា ដល់កុមារម្នាក់ ចំនួន ៨០,០០០៛ (ប្រាំបីម៉ឺនរៀល) ក្នុង១ខែ ដើម្បីអាចទទួលបានការសិក្សាយ៉ាងតិចប្រាំបួនឆ្នាំ រួមទាំងកម្មវិធីផ្តល់

ប្រាក់កម្ចី ដោយមិនយកការប្រាក់ ឲ្យបានយ៉ាងតិចបំផុត៥ម៉ឺននាក់ក្នុងមួយឆ្នាំ សម្រាប់និស្សិតក្រីក្រដែលចង់បន្តការសិក្សានៅតាមមហាវិទ្យាល័យ ឬតាមសាលាបច្ចេកទេស ហើយអាចសងរដ្ឋវិញ ជាដំណាក់កាលបន្តិចម្តងៗ ក្នុងចន្លោះពេលពី១០-១៥ឆ្នាំ ក្រោយពេលបញ្ចប់ការសិក្សានិងមានការងារធ្វើត្រឹមត្រូវ។

**២.៤.**បង្កើនកម្មវិធីអាហារូបករណ៍ ទាំងក្នុង និងក្រៅប្រទេស ឲ្យបាន ១ម៉ឺននាក់ ក្នុងមួយឆ្នាំ សម្រាប់សិស្សនិស្សិតរៀនពូកែ។

**២.៥.**ជំរុញ និងលើកទឹកចិត្តឲ្យមានសាលាឯកទេសជំនាញឬ/និងមានសកលវិទ្យាល័យ នៅគ្រប់ខេត្តក្រុង ស្រុក ដើម្បីបង្កភាពងាយស្រួលដល់កូនអ្នករស់នៅជនបទ អាចមានលទ្ធភាពចូលរៀនបានគ្រប់គ្នា។ កសាង និងពង្រាយសាលារៀនគ្រប់កម្រិត ឲ្យស្រប

តាមបរិមាណសិស្ស និងតាមតំបន់ភូមិសាស្ត្រ ដោយមានគម្រោងផែនការជាក់លាក់ និងជំរុញឲ្យមានមតេយ្យសាលាសម្រាប់អប់រំ និងថែរក្សាកូនក្មេងឲ្យបានគ្រប់ឃុំ។

**២.៦.**លើកកម្ពស់តម្លៃគ្រូបង្រៀន ដោយដំឡើងប្រាក់បៀវត្សជូនលោកគ្រូ-អ្នកគ្រូ យ៉ាងតិច ២,០០០,០០០៛ (ពីរលានរៀល) ក្នុងមួយខែ និងផ្តល់ថវិកាសម្រាប់សម្ភារៈអប់រំ និងសិក្សាស្រាវជ្រាវឲ្យបានគ្រប់គ្រាន់។ ផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមចំពោះលោកគ្រូ-អ្នកគ្រូ ដែលស្ម័គ្រចិត្តទៅបង្រៀននៅតំបន់ជនបទដាច់ស្រយាល។ ពង្រឹងគុណភាពអប់រំ តាមរយៈការពង្រឹងក្រមសីលធម៌ និងសមត្ថភាពលោកគ្រូ-អ្នកគ្រូ។

**២.៧.**ផ្តល់ការអប់រំផ្នែក សីលធម៌ល្អ កិច្ចការសង្គម ការពារបរិស្ថានធនធានធម្មជាតិ ការថែរក្សាវប្បធម៌ និងកិច្ចការពាបេតិកភណ្ឌជាតិ។

**២.៨.**តម្រូវវិស័យអប់រំឯកជន អនុវត្តនិយាមគរុកោសល្យឲ្យបានត្រឹមត្រូវ មានកម្មវិធីសិក្សាសាលាមានទីធ្លាសម្រាប់សិស្សស្រូបយកខ្យល់អាកាស និងលេងកីឡាជាដើម។

**២.៩.**តម្រូវឲ្យសិស្សរៀនពេញ ១ថ្ងៃ (ទាំងព្រឹកទាំងល្ងាច)។

## ៣- ផ្នែកការងារ

### ចក្ខុវិស័យ

*រដ្ឋមានកាតព្វកិច្ច ក្នុងការបង្កើតការងារត្រឹមត្រូវ ដែលមានប្រាក់ចំណូលសមស្រប ក្នុងការទ្រទ្រង់ ជីវភាពរស់នៅប្រកបដោយកិត្តិយស និងសេចក្ដីថ្លៃថ្នូរ ដល់ពលរដ្ឋខ្មែរ។*

**៣.១.** រាជរដ្ឋាភិបាលដឹកនាំដោយ **គណបក្ស ភ្លើងទៀន** មានភារកិច្ចសំខាន់ និងបន្ទាន់ ក្នុងការអនុវត្តនូវកម្មវិធីនយោបាយដែលមានប្រសិទ្ធភាពក្នុងការបង្កើតការងារធ្វើត្រឹមត្រូវ មានប្រាក់ចំណូលសមរម្យដល់ពលរដ្ឋខ្មែរ។ សព្វថ្ងៃប្រជាពលរដ្ឋជាច្រើនដែលពុំមានការងារធ្វើត្រឹមត្រូវ មានចំនួនកាន់តែច្រើនឡើងៗ ដែលនាំឲ្យពួកគេបង្ខំចិត្តធ្វើចំណាកស្រុកទៅធ្វើការ

នៅក្រៅប្រទេស ឆ្ងាយពីក្រុមគ្រួសារ និងទទួលរងការលំបាកគ្រប់បែបយ៉ាង។

**៣.២.**ការងារធ្វើត្រឹមត្រូវ ទទួលបានប្រាក់កម្រៃយ៉ាងតិច ១លាន២សែនរៀល ក្នុងមួយខែ នៅទីកន្លែងមានបរិយាកាសធានាសុវត្ថិភាព និងសុខភាពផ្ទាល់ខ្លួន។

**៣.៣.** រាជរដ្ឋាភិបាលដឹកនាំដោយ **គណបក្សភ្លើងទៀន** នឹងចាប់ផ្តើមនយោបាយបង្កើតការងារ ១លានកន្លែងក្នុង ១អាណត្តិ តាមរយៈការជំរុញក្រុមហ៊ុនដែលទទួលបានដីសម្បទាន ធ្វើការអភិវឌ្ឍលើដីធ្លីតាមកិច្ចសន្យា មានការដាំដុះដំណាំកសិឧស្សាហកម្មជាដើម និងការលើកទឹកចិត្តឲ្យមានការវិនិយោគលើវិស័យឧស្សាហកម្ម ដែលប្រើប្រាស់វត្ថុធាតុដើម និងផលិតផលកសិកម្មក្នុងស្រុកសម្រាប់ការនាំចេញ។

៣.៤.ការស្រាវជ្រាវលើព័ត៌មានទីផ្សារការងារដោយសហការជាមួយអង្គការពលកម្មអន្តរជាតិ (ILO) និងសហគ្រាសឯកជន ដើម្បីជាមូលដ្ឋានព័ត៌មានក្នុងការរៀបចំកម្មវិធីហ្វឹកហ្វឺនជំនាញដល់ពលករឲ្យបានគ្រប់គ្រាន់និងទាន់ពេលវេលាសម្រាប់បំពេញសេចក្តីត្រូវការនៃទីផ្សារការងារដែលនឹងទាក់ទាញវិនិយោគទុនពីបរទេសបានច្រើន។

៣.៥.រាជរដ្ឋាភិបាលដឹកនាំដោយ **គណបក្សភ្លើងទៀន** នឹងលុបបំបាត់អំពើពុករលួយ និងការិយាធិបតេយ្យឲ្យមានប្រសិទ្ធភាព ដើម្បីធានាការផ្តល់សេវាល្អត្រឹមត្រូវឆាប់រហ័សដល់ កិច្ចការវិនិយោគទុន និងអនុវត្តឲ្យបានត្រឹមត្រូវនូវលក្ខខណ្ឌកំណត់ដោយសហគមន៍អឺរ៉ុប(EBA) និងសហរដ្ឋអាមេរិក(GSP)ជាដើមដើម្បីទទួលបានការអនុគ្រោះពន្ធសម្រាប់ការនាំចេញ

ផលិតផល។ លើកស្ទួយដល់ការធ្វើពាណិជ្ជកម្មធុនតូច និងកណ្តាល សម្រាប់ការផលិតបម្រើសេចក្តីត្រូវការក្នុងស្រុក និងការនាំចេញទៅបរទេស។

**៣.៦.**រាជរដ្ឋាភិបាលដឹកនាំដោយ **គណបក្សភ្លើងទៀន** នឹងបង្កើតឲ្យមានច្បាប់ស្តីពី ″សហគ្រាសរដ្ឋទំនាក់ទំនងពលករ″ (State Enterprise Labour Relations) សម្រាប់ជួយដល់សហជីពក្នុងប្រទេស ដើម្បីពង្រឹងសមត្ថភាពលើកិច្ចការចចារការពារសិទ្ធិ និងផលប្រយោជន៍ពលករ រួមទាំងការហ្វឹកហ្វឺនជំនាញដល់ពលករផង។

**៣.៧.**នៅមុនការបង្កើតការងារត្រឹមត្រូវក្នុងស្រុកបានគ្រប់គ្រាន់រាជរដ្ឋាភិបាលដឹកនាំដោយ **គណបក្ស ភ្លើងទៀន** នឹងរៀបចំឲ្យមានការផ្តល់ឯកសារនៅតាមមូលដ្ឋានឃុំ-សង្កាត់មានលិខិតឆ្លងដែន និងឯកសារ

សម្រាប់ប្រើប្រាស់ដើម្បីទៅធ្វើការដោយស្របច្បាប់ នៅក្រៅប្រទេសដោយឆាប់រហ័សក្នុងតម្លៃទាបសម្រាប់ពលករខ្មែរ។

## ៤- ផ្នែកសេវាសុខាភិបាល

### ចក្ខុវិស័យ

*គ្មានពលរដ្ឋខ្មែរណាម្នាក់ត្រូវបានទុកឲ្យស្លាប់ដោយសារពុំមានប្រាក់ព្យាបាលជំងឺនោះទេ រដ្ឋាភិបាលត្រូវផ្តល់សេវាព្យាបាលជំងឺត្រឹមត្រូវដោយឥតគិតថ្លៃចំពោះពលរដ្ឋដែលមកព្យាបាលសុខភាពនៅមន្ទីរពេទ្យរដ្ឋ ព្រមទាំងផ្តល់នូវប្រព័ន្ធទឹកស្អាត ប្រព័ន្ធអនាម័យ និងសេវាចាំបាច់ផ្សេងទៀតជាមួយនឹងការផ្តល់ការអប់រំផ្នែកសុខភាពរបស់ពលរដ្ឋគ្រប់រូបជាដើម។*

**៤.១.គណបក្ស ភ្លើងទៀន** មានគោលនយោបាយ ធ្វើការកែទម្រង់ក្នុងវិស័យសុខាភិបាល ៦ ចំណុចសំខាន់ដូចខាងក្រោម ៖

១-រៀបចំឲ្យមន្ទីរពេទ្យ របស់រដ្ឋទាំងអស់ពិនិត្យ និងព្យាបាលជំងឺ ជូនពលរដ្ឋដោយឥតបង់ប្រាក់ ជាមួយការព្យាបាលអ្នកជំងឺបានត្រឹមត្រូវ ដោយមានគ្រូពេទ្យប្រកបដោយជំនាញ និងមានក្រមសីលធម៌វិជ្ជាជីវៈ រួមទាំងមានថ្នាំពេទ្យ និងបរិក្ខារពេទ្យគ្រប់គ្រាន់។ រាជរដ្ឋាភិបាលដឹកនាំដោយ **គណបក្ស ភ្លើងទៀន** នឹងបង្កើតឲ្យមានមជ្ឈមណ្ឌលថែទាំសុខភាពមាតា និងទារកតាមមូលដ្ឋាន ដើម្បីផ្តល់ការថែទាំដល់មាតា មុន និងក្រោយសម្រាលកូនឲ្យបានល្អ។

**៤.២.**បង្កើតប្រព័ន្ធការពារសុខភាពដែលផ្តោតលើការរស់នៅរបស់ពលរដ្ឋ ប្រកបដោយសុខមាលភាព

តាមរយៈការទទួលទានម្ហូបអាហារល្អ ដែលមានអនាម័យ គ្មានជាតិគីមី និងមានជីវជាតិគ្រប់គ្រាន់ ហើយរស់នៅ និងធ្វើការងារក្នុងបរិស្ថានដែលមានសុវត្ថិភាព និង បរិយាកាសល្អ ដែលជៀសផុតពីការបៀតបៀនដោយ ជំងឺឆ្លងផ្សេងៗ។ កម្មវិធីនេះ ចាំបាច់ត្រូវផ្តោតទៅលើ ការធ្វើកំណែទម្រង់ច្បាប់មួយចំនួន ដើម្បីទប់ទល់ការ លក់ឱសថក្លែងក្លាយ បញ្ឈប់និងទប់ស្កាត់ការព្យាបាល ជំងឺដែលគ្មានជំនាញត្រឹមត្រូវ និងដោយរបៀបកេង ប្រវ័ញ្ច។ ការរៀបចំប្រព័ន្ធទឹកស្អាត និងត្រួតពិនិត្យជាតិ គីមីនៅក្នុងម្ហូបអាហារ ជាដើម។

**៤.៣.**បង្កើតបែបបទគ្រប់គ្រងមួយ និងការពារសុខ ភាពពលរដ្ឋពីផលប៉ះពាល់ ដែលអាចកើតមានឡើង តាមរយៈសកម្មភាពសេដ្ឋកិច្ច និងការអភិវឌ្ឍនានា ជាមួយនឹងការបង្កើតប្រព័ន្ធធានារ៉ាប់រងសុខភាព ដែល

ពលរដ្ឋនឹងទទួលបាននូវសេវាព្យាបាលជំងឺ ដែលមានគុណភាពជាលក្ខណៈសកល ហើយនឹងមិនយកកម្រៃ។

**៤.៤.**ពង្រឹងការអប់រំដល់ប្រជាពលរដ្ឋឲ្យយល់ច្បាស់អំពីសក្ដានុពលក្នុងការថែរក្សាសុខភាព ដោយបង្កើតឲ្យមានការចូលរួម និងរៀនសូត្រនៅតាមមូលដ្ឋាន។ កម្មវិធីការពារសុខភាព ជាសកម្មភាពសំខាន់ក្នុងការថែរក្សាសុខភាព ហេតុនេះចាំបាច់ត្រូវបន្ថែមឲ្យមានការផ្សព្វផ្សាយព័ត៌មាន ផ្នែកថែទាំសុខភាពដល់ប្រជាពលរដ្ឋឲ្យបានទូលំទូលាយ។

**៤.៥.**កសាងក្រុមជំនាញវិជ្ជាជីវៈពេទ្យ ដែលមានសមត្ថភាព ដោយផ្ដល់ប្រាក់បៀវត្សសមរម្យ ហើយបំពេញតួនាទីក្នុងអាជីព ដោយឲ្យសច្ចានិងធានាថាជាគ្រូពេទ្យត្រូវព្យាបាលជម្ងឺ ដោយគោរពតាមក្រមសីលធម៌វិជ្ជាជីវៈត្រឹមត្រូវ។

**៤.៦.**រៀបចំយន្តការក្នុងប្រព័ន្ធរដ្ឋបាលរបស់ក្រសួងសុខាភិបាលឲ្យមានតម្លាភាព។ ជាចាំបាច់ត្រូវជំរុញការធ្វើវិមជ្ឈការនៅក្នុងវិស័យសុខាភិបាលសាធារណៈ ជាមួយការបង្កើតអាជ្ញាធរមួយសម្រាប់ទទួលខុសត្រូវក្នុងការអភិវឌ្ឍប្រព័ន្ធការពារសុខភាព ដែលឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ដោយសហការជាមួយអង្គការក្រៅរដ្ឋាភិបាល និងជួយជំរុញឲ្យអង្គភាពពាក់ព័ន្ធទាំងក្នុងប្រព័ន្ធសាធារណៈ និងប្រព័ន្ធឯកជន ធ្វើការងារស្របគ្នា ដើម្បីបំពេញសេចក្តីត្រូវការរបស់មូលដ្ឋាន។ **ត្រូវបង្កើតអង្គភាពសវនកម្មសម្រាប់វិស័យសុខាភិបាលសាធាណៈក្នុងការទទួលពាក្យបណ្តឹង និងត្រួតពិនិត្យស្តង់ដាររបស់មន្ទីរពេទ្យ និងមន្ទីរសុខភាព។** បទដ្ឋានស្តង់ដារសុខាភិបាលសាធារណៈ នឹងត្រូវចែងឲ្យបានច្បាស់លាស់ក្នុងច្បាប់។

## ៥- ផ្នែកកសិកម្ម

### ចក្ខុវិស័យ

*ជីវភាពកសិករខ្មែរត្រូវតែទទួលបានការលើកតម្កើង និងធានាដោយរដ្ឋ តាមរយៈការមានដីធ្លីគ្រប់គ្រាន់សម្រាប់ការបង្កបង្កើនផលតាមបច្ចេកទេស ដែលទទួលបានទិន្នផលច្រើន និងមានទីផ្សារ សម្រាប់លក់បានចំណេញត្រឹមត្រូវ។*

**៥.១.**យុទ្ធសាស្ត្រទូលំទូលាយ ក្នុងវិស័យកសិកម្ម ដែលទិសដៅដំបូង គឺពង្រឹងនូវលទ្ធភាពនៃការប្រកួតប្រជែងនៃកសិករខ្មែរ នៅលំដាប់ទីផ្សារ។ វិធីដែលមានប្រសិទ្ធភាព និងចីរភាពសម្រាប់កសិករ គឺផ្តល់នូវការលើកទឹកចិត្តដល់កសិករក្នុងការបង្កើតផលិតផល ដែលមានគុណភាពខ្ពស់សម្រាប់លក់ក្នុង

តម្លៃអាចប្រកួតប្រជែងបានក្នុងនោះ រដ្ឋត្រូវទប់ស្កាត់ការនាំចូលផលិតផលកសិកម្មដែលគ្មានគុណភាព មានផ្ទុកជាតិគីមី សារធាតុពុល និងជួយផ្តល់ការឧបត្ថម្ភធនធានដល់កសិករខ្មែរ។

**៥.២.**តាមពិតកសិករខ្មែរមានបញ្ហាមួយចំនួនដែលត្រូវយកចិត្តទុកដាក់ ដូចជា ការខ្វះកិច្ចការពារលើសិទ្ធិជាម្ចាស់ដីស្រែចំការ និងការមានលទ្ធភាពតិចតួចដើម្បីបង្កើនការផលិតឲ្យលើសពីការផលិតសម្រាប់តែការផ្គត់ផ្គង់ក្នុងគ្រួសារ ការមិនយល់ដឹងពីបច្ចេកទេស និងទីផ្សារជាដើម។ គោលនយោបាយត្រូវការសកម្មភាពចូលរួមយ៉ាងខ្លាំង ពីស្ថាប័នរដ្ឋាភិបាល និងរដ្ឋបាលមូលដ្ឋានរួមទាំងអ្នកវិនិយោគទុនជាដើម ក្នុងការជំរុញឲ្យមានការផ្តល់ជំនាញដល់កសិករ ការរកទីផ្សារលក់ផលិតផល និងការផលិតជី និងចំណីសត្វក្នុង

ស្រុកដោយធានាបាននូវតម្លៃទាបអាចឲ្យកសិករកាត់បន្ថយការចំណាយនៃការផលិត។

**៥.៣.**ការរៀបចំឲ្យមាននយោបាយជាវិធានការណ៍ដ៏មានប្រសិទ្ធភាព ក្នុងការអនុវត្តជួយដល់កសិករខ្មែរឲ្យមានជីវភាពធូរធារឆាប់រហ័សជាបន្ទាន់នោះ រាជរដ្ឋាភិបាលដឹកនាំដោយ **គណបក្ស ភ្លើងទៀន** ជំរុញឲ្យមានការដោះស្រាយលើបញ្ហាមួយចំនួន ដូចតទៅ ៖

**(ក)-បញ្ហាដីធ្លី**

-ត្រូវធ្វើការពិនិត្យលើដីធ្លីដែលរដ្ឋាភិបាល បច្ចុប្បន្ន ផ្តល់ជាសម្បទានយ៉ាងយូរដែលមានរហូតដល់ ៩៩ឆ្នាំ ឲ្យទៅក្រុមហ៊ុន ហើយបើពិនិត្យតាមផ្លូវច្បាប់រកឃើញថា មានភាពមិនត្រឹមត្រូវ ឬអាចប៉ះពាល់ដល់បូរណភាពទឹកដី ឬក្រុមហ៊ុនពុំបានអនុវត្តន៍តាមកិច្ច

សន្យានោះ រដ្ឋត្រូវមានវិធានការដកយកដីទាំងនេះទុកជាសម្បត្តិរដ្ឋ រួចអាចធ្វើការបែងចែកជូនទៅគ្រួសារកសិករដែលគ្មានដីធ្លី ឬធ្វើការដាំដើមឈើឡើងវិញ។

-ត្រូវផ្តល់ដីធ្លីដែលអ្នកមានអំណាច ឬក្រុមហ៊ុនបានរំលោភយក ប្រគល់សងជូនពលរដ្ឋជាម្ចាស់វិញ។

**(ខ)-កាត់បន្ថយការចំណាយលើការផលិត**

-លើកទឹកចិត្តបន្ថែមទៀតដល់"**ការបង្កើតសហគមន៍កសិករ**" ដោយមានការឧបត្ថម្ភជា ថវិការ ជំនាញ និងទីផ្សារលក់ផលិតផលពីរដ្ឋ រួមទាំងកិច្ចសហការល្អជាមួយអង្គការក្រៅរដ្ឋាភិបាល ហើយ អាចឲ្យកសិករទិញសម្ភារៈកសិកម្មរួមគ្នាមានតម្លៃថោក និងការលក់ផលិតផលបានថ្លៃ។

-កំណត់តម្លៃប្រេងឥន្ធនៈ ជីកសិកម្ម សម្ភារៈកសិកម្ម និងថ្នាំសម្លាប់សត្វល្អិតឲ្យមានតម្លៃទាប ឬប្រហាក់ប្រហែលនឹងប្រទេសជិតខាង។

-លុបបំបាត់សិទ្ធិផ្តាច់មុខ នៃការនាំចេញ ទិញ ឬលក់ផលិតផល និងសម្ភារៈកសិកម្ម។

-សម្រួលដល់ការដឹកជញ្ជូនផលិតផលកសិកម្ម ដោយលុបបំបាត់ការឃាត់តថយន្តទារប្រាក់ពីអាជ្ញាធរគ្រប់លំដាប់ថ្នាក់។

-បង្កើតនាយកដ្ឋាន ឬស្ថាប័នជាន់ខ្ពស់មួយ ដើម្បីជួយទ្រទ្រង់ដល់សហគមន៍កសិករ។

-ជំរុញការបង្កើតរោងចក្រផលិតជី និងម្ហូបសត្វក្នុងស្រុកដើម្បីធានាឲ្យមានតម្លៃថោក។

-លុបចោលទាំងស្រុង ការយកពន្ធ លើការនាំចេញ ផលិតផលកសិកម្ម។

**(គ)-ជំនួយបច្ចេកទេស**

-បញ្ចូលក្នុងកម្មវិធីសិក្សាដោយផ្តល់ការហ្វឹកហ្វឺន បច្ចេកទេសកសិកម្ម ដល់សិស្សសាលា ដោយឲ្យពួក គេបានយល់ពីបច្ចេកទេសថ្មីនៃការដាំដុះ ដើម្បីអាច ជួយឪពុកម្តាយក្នុងការធ្វើឲ្យប្រសើរឡើងនូវការ ផលិតផលដំណាំ។

-ត្រូវបង្កើនថវិកាជាតិសម្រាប់វិស័យកសិកម្ម ដើម្បីផ្តល់មធ្យោបាយ ដល់មន្ត្រីបច្ចេកទេសកសិកម្ម អាចចុះជួយដល់កសិករលើផ្នែកបច្ចេកទេសដាំដុះ ប្រើ ប្រាស់ជី និងថ្នាំកំចាត់សត្វល្អិត រួមទាំងផ្តល់ចំណេះដឹង ផ្នែកទីផ្សារលក់ផលិតផលផង។

-ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយមាន វិទ្យុ និង ទូរទស្សន៍របស់រដ្ឋ និងឯកជន ដើម្បីផ្តល់ព័ត៌មានទី

ផ្សារ និងចំណេះបច្ចេកទេសទៀងទាត់ និងទាន់ពេលវេលាដល់កសិករ។

**(ឃ)-ព័ត៌មាន និងទីផ្សារលក់ផលិតផល**

-រាជរដ្ឋាភិបាលដឹកនាំដោយ**គណបក្ស ភ្លើងទៀន** ជំរុញឲ្យមានការបង្កើតការិយាល័យកសិកម្មតាមមូលដ្ឋាន ដែលមានទីតាំងនៅគ្រប់ឃុំដោយផ្តល់ថវិកាគ្រប់គ្រាន់សម្រាប់បំពេញការងាររបស់ខ្លួនឲ្យមានប្រសិទ្ធភាព។ ការិយាល័យនេះ នឹងបម្រើសេវាច្រើនយ៉ាងដល់កសិករមូលដ្ឋាន ដូចជា៖ ប្រមូលតួលេខ នៃតម្លៃផលិតផលកសិកម្មនៅទីផ្សារ ដើម្បីបញ្ចូលប្រព័ន្ធទូរស័ព្ទដៃផ្តល់ទៅកសិករ និងបិទបញ្ជីតម្លៃទំនិញប្រចាំថ្ងៃនេះនៅការិយាល័យផង។ ការិយាល័យកសិកម្មឃុំរៀបចំឲ្យមានការអប់រំដល់កសិករនូវចំណេះដឹងពីដំណាំឆ្លាស់គ្នា ការផលិតជីធម្មជាតិ និងចំណីសត្វ ការ

ប្រើប្រាស់ជី និងថ្នាំកំចាត់សត្វល្អិត។ ការិយាល័យកសិកម្ម អាចជួយហ្វឹកហ្វឺនដល់កសិករ និងយុវជនតាមភូមិ ដែលគ្មានការងារធ្វើនូវបច្ចេកទេសដាំដុះថ្មីៗមានប្រសិទ្ធភាព និងតាមតម្រូវការទីផ្សារ ដើម្បីឲ្យគេអាចជួយឪពុកម្តាយបង្កើនការផលិត ដោយអនុវត្តការផលិតតាមបែបបច្ចេកទេសថ្មី មួយការងារថែទាំ និងប្រើប្រាស់ប្រព័ន្ធធារាសាស្រ្តឲ្យបានល្អ។

**(ង)-ការខ្វះប្រព័ន្ធធារាសាស្រ្ត**

-រាជរដ្ឋាភិបាលដឹកនាំដោយ **គណបក្ស ភ្លើងទៀន** ជំរុញឲ្យមាន ការផ្តល់មធ្យោបាយដល់រដ្ឋបាលមូលដ្ឋានតាមខេត្តនានា ក្នុងការធ្វើឲ្យមានការគ្រប់គ្រងប្រព័ន្ធធារាសាស្រ្ត ប្រកបដោយការទទួលខុសត្រូវ និងមានប្រសិទ្ធភាព។

-រៀបចំឲ្យមានថវិកា សម្រាប់ជួយដល់សហគមន៍កសិករ និងអាជ្ញាធរមូលដ្ឋាន ដើម្បីចូលរួមថែទាំប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ និងធ្វើការជីកប្រឡាយតូចៗតភ្ជាប់ប្រព័ន្ធមេទៅស្រែពលរដ្ឋ រួមទាំងប្រើប្រាស់ថវិកានេះ សម្រាប់ការបង្កើតប្រព័ន្ធធារាសាស្ត្រខ្នាតតូច តាមសេចក្តីត្រូវការជាក់លាក់។

-ផ្តល់លទ្ធភាពដល់សហគមន៍កសិករ ក្នុងការទទួលបានការហ្វឹកហ្វឺនសម្រាប់ការបង្កើត និងថែទាំប្រឡាយតូចៗ ដែលតភ្ជាប់ពីប្រព័ន្ធធារាសាស្ត្រមេទៅស្រែចំការ។

-លុបចោល**ក្រសួងធនធានទឹក និងឧត្តុនិយម** ដោយយកផ្នែកធនធានទឹក មកបញ្ចូលជាអគ្គនាយកដ្ឋានមួយ ក្នុងក្រសួងកសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទវិញ។

**(ច)-កាត់បន្ថយអត្រាការប្រាក់ខ្ពស់**

-ជួយកសិករ ក្នុងការរកការឧបត្ថម្ភពីរាជរដ្ឋាភិបាល និងអង្គការផ្សេងៗផង និងខ្ចីប្រាក់ពីធនាគារដែលមានការប្រាក់ទាប រួមទាំងអាចរកទីផ្សារលក់ផលិតផលរួមបានតម្លៃខ្ពស់ជាដើម។

-កម្មសិទ្ធិដីធ្លី ត្រូវផ្តល់ឲ្យទៅកសិករគ្រប់គ្នាយ៉ាងឆាប់បំផុត ដើម្បីពួកគេអាចប្រើប្រាស់សម្រាប់ការខ្ចីប្រាក់ពីធនាគារបានក្នុងកម្រិតការប្រាក់ទាបជាងការខ្ចីបុលពីឯកជន។

-រាជរដ្ឋាភិបាលដឹកនាំដោយ**គណបក្ស ភ្លើងទៀន** នឹងបង្កើតច្បាប់ដើម្បីគ្រប់គ្រងអាត្រាការប្រាក់នៃការចងការប្រាក់ជាឯកជន កុំឲ្យឈ្មួញដាក់តម្លៃខ្ពស់ហួសហេតុពេក និងប្រើប្រាស់ស្ថាប័នមីក្រូហិរញ្ញវត្ថុរដ្ឋសម្រាប់ជួយដល់កសិករតាមរយៈសហគមន៍ ឬសមាគម ក្នុងអត្រាការប្រាក់ទាប។

## ៦-ផ្នែកការពារទ្រព្យសម្បត្តិជាតិនិងបរិស្ថាន

**៦.១.**ធ្វើបញ្ជីទ្រព្យសម្បត្តិធនធានរបស់ជាតិ ឲ្យបានច្បាស់លាស់ជាបន្ទាន់ និងដោយតម្លាភាព ហើយយកដាក់ជាសម្បត្តិរដ្ឋវិញ នូវ បឹង ដី ព្រៃឈើ និងអគាររបស់រដ្ឋ ដែលអ្នកមានអំណាច ឬឈ្មួញរំលោភយកដោយខុសច្បាប់។

**៦.២.**ធ្វើការគ្រប់គ្រងធនធានធម្មជាតិនិងរ៉ែ ដូចជា ខ្សាច់ ប្រេងកាត ត្បូង មាស ទង់ដែង ដែក និងព្រៃឈើ ឲ្យមានប្រសិទ្ធភាព ដើម្បីជាប្រយោជន៍ជាតិដល់ប្រជាពលរដ្ឋទូទៅ។

**៦.៣.**រាល់ការរុករក និងធ្វើអាជីវកម្មរ៉ែ ត្រូវដាក់ឲ្យមានការដេញថ្លៃពីក្រុមហ៊ុនឯកជននានា ដោយមានតម្លាភាព ហើយរដ្ឋ និងក្រុមហ៊ុនត្រូវប្រកាសពីចំណូល និងចំណាយជាប្រចាំ និងជាសាធារណៈ។

**៦.៤.**រាល់ការអនុវត្តអាជីវកម្មរ៉ែ ការសាងសង់វារីអគ្គីសនី ការសាងសង់រោងចក្រ សហគ្រាស និង ហេដ្ឋារចនាសម្ព័ន្ធតូចធំផ្សេងៗ ត្រូវតែមានការសិក្សាអំពីផលប៉ះពាល់បរិស្ថានសង្គម និងបរិស្ថានធម្មជាតិឲ្យបានច្បាស់លាស់ជាមុនសិនមុននឹងមានអនុញ្ញាត។

**៦.៥.**ការពារឲ្យមាននិរន្តរភាពធនធានធម្មជាតិ និងនិរន្តរភាពបរិស្ថានធម្មជាតិតាមរយៈ ៖

(ក)-ទប់ស្កាត់ការនេសាទខុសច្បាប់បង្កើតឲ្យមានតំបន់អភិរក្សត្រីធម្មជាតិ និងរៀបចំពង្រឹងសហគមន៍នេសាទ ដើម្បីគ្រប់គ្រងដែននេសាទ ប្រកបដោយប្រសិទ្ធភាព។

(ខ)-ស្តារប្រព័ន្ធផ្លូវទឹកធម្មជាតិដូចជាទន្លេ ព្រែកស្ទឹង ដើម្បីធានាចរាចរបន្តពូជមច្ឆជាតិ។

(គ)បញ្ឈប់ទាំងស្រុងការផ្តល់ដីសម្បទានសេដ្ឋកិច្ច និងយកមកជាសម្បត្តិរដ្ឋវិញ នូវដីសម្បទានសេដ្ឋកិច្ចណាដែលក្រុមហ៊ុនឯកជនមិនបានអនុវត្តតាមកិច្ចសន្យា ឬនិងការរធ្វើសម្បទានដីទាំងនោះអាចប៉ះពាល់ដល់បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។

(ឃ)ចាត់វិធានការម៉ឺងម៉ាត់ ទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើ និងបញ្ឈប់ទាំងស្រុងការនាំឈើចេញទៅក្រៅប្រទេស និងទប់ស្កាត់ការជួញដូរសត្វព្រៃ ដោយការអនុវត្តច្បាប់តឹងតែង ហើយបង្កើនកិច្ចសហការល្អ ជាមួយអង្គការការពារបរិស្ថាន និងពង្រឹងការងារសហគមន៍ព្រៃឈើ ដើម្បីគ្រប់គ្រង និងប្រើប្រាស់ធនធានព្រៃឈើ ប្រកបដោយនិរន្តរភាព។

(ង)-រដ្ឋចាត់វិធានការដាំដើមឈើទូទាំងប្រទេសឡើងវិញ ជាពិសេសនៅលើដីសម្បទានដែលយកពី

ក្រុមហ៊ុនបានមកវិញ និងនៅតាមមាត់បឹងទន្លេ ដែលត្រូវគេកាប់បំផ្លាញ និងបំផុសឲ្យមានការចូលរួមថែទាំទាំងអស់គ្នា ដើម្បីការពារបរិស្ថាន និងចូលរួមជាមួយសហគមន៍អន្តរជាតិ ដើម្បីកាត់បន្ថយការឡើងកំដៅពិភពលោក (Global Warming)។

## ៧-កិច្ចការពារជាតិនិងការគ្រប់គ្រងប្រទេស

**៧.១.**អ្នកដឹកនាំសំខាន់ៗរបស់ជាតិ ត្រូវមានសញ្ញាតិខ្មែរ ពីឪពុកនិងម្តាយ ដែលមានសញ្ញាតិ ខ្មែរពីដើមកំណើត។

-ប្រកាន់យកការស្រុះស្រួល និងឯកភាពជាតិក្នុងការដោះស្រាយ តាមរយៈការសន្ទនាជាមូលដ្ឋាន រវាងគណបក្សកាន់អំណាច និងគណបក្សប្រឆាំង ក្នុងការ

ដោះស្រាយវិបត្តិនយោបាយ វិបត្តិសង្គម វិបត្តិសេដ្ឋកិច្ច និងជម្លោះជាមួយប្រទេសជិតខាង។

**៧.២**.អប់រំ និងផ្សព្វផ្សាយ ឲ្យបានទូលំទូលាយ នូវសីលធម៌ វប្បធម៌ ពលរដ្ឋវិជ្ជា អក្សរសាស្ត្រ ប្រវត្តិសាស្ត្រ ប្រពៃណី ទំនៀមទម្លាប់ សាសនាជាតិ និងស្មារតីស្នេហាជាតិ តាមរយៈកម្មវិធីសិក្សា សិល្បៈ វិទ្យុ ទូរទស្សន៍ សារព័ត៌មាន និងផ្ទាំងផ្សព្វផ្សាយសាធារណៈ។

**៧.៣**.ចាត់វិធានការ ដើម្បីលុបបំបាត់ឲ្យបានជាដាច់ខាត នូវការរើសអើងរវាងខ្មែរនិងខ្មែរ ការរើសអើងជាតិសាសន៍ ជាមួយការកម្ចាត់ការជួញដូរមនុស្ស ការជួញដូរគ្រឿងញៀន ការលេងល្បែងស៊ីសងគ្រប់ប្រភេទ ការបំបាត់អំពើហិង្សាក្នុងគ្រួសារ បងតូចបងធំ និងអំពើពាលាអាវ៉ាសែដទៃទៀត។

**៧.៤.**បដិសេធចោលនូវរាល់ការផ្តល់សញ្ជាតិខ្មែរឲ្យជនបរទេសណា ដែលធ្វើឡើងដោយខុសច្បាប់ ជាធរមាន។

**៧.៥.**ការពង្រឹងសីលធម៌ល្អ តាមរយៈការស្នើផ្តល់គ្រឿងឥស្សរិយស និងគោរមងារឲ្យចំពោះតែបុគ្គល ឬក្រុមពលរដ្ឋដែលបានធ្វើទង្វើល្អជាប្រយោជន៍ដល់សង្គម និងប្រទេសជាតិប៉ុណ្ណោះ។

**៧.៦.**<u>ការពារប្រពៃណី ភាសា និងដីសហគមន៍ជនជាតិដើមឲ្យបានគង់វង្ស។</u>

**៧.៧.**កំណត់អាណត្តិនាយករដ្ឋមន្ត្រី ដោយបុគ្គលម្នាក់ មិនអនុញ្ញាតឲ្យធ្វើនាយករដ្ឋមន្ត្រីលើសពី ២ អាណត្តិ ឬស្មើ ១០ឆ្នាំ។

**៧.៨.**ពង្រឹងស្ថាប័នប្រជាធិបតេយ្យ និងធ្វើឲ្យមានតុល្យភាពអំណាច និងបែងចែកអំណាចដាច់ពីគ្នា រវាង

អំណាចនីតិប្រតិបត្តិ អំណាចនីតិប្បញ្ញត្តិ និងអំណាចតុលាការ។ បែងចែកឲ្យដាច់ពីគ្នាក្នុងការគ្រប់គ្រងរដ្ឋ និងបក្ស ដែលក្នុងនោះប្រធានតុលាការ និងព្រះរាជអាជ្ញាគ្រប់លំដាប់ថ្នាក់ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមិនត្រូវជាសមាជិក ឬជាអតីតសមាជិក ថ្នាក់ដឹកនាំគណបក្សនយោបាយទេ។

**៧.៩.**បង្កើតនូវវប្បធម៌ប្រជាធិបតេយ្យ ដោយផ្ទាល់តាមរយៈការបើកឲ្យមានវេទិកាជួបសួរដេញដោល ជាសាធារណៈ រវាងអ្នកដឹកនាំរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ជាមួយប្រជាពលរដ្ឋ ហើយធ្វើប្រជាមតិចំពោះសេចក្តីសម្រេចធំៗរបស់ជាតិ។

**៧.១០.**បង្កើតនូវក្រុមសីលធម៌សម្រាប់អ្នកដឹកនាំ ដោយតម្រូវឲ្យអ្នកដឹកនាំដែលមានកំហុសឆ្គង ប៉ះពាល់ដល់ផលប្រយោជន៍ប្រទេសជាតិ ឬប្រយោជន៍ប្រជាពលរដ្ឋក្នុងកម្រិតណាមួយ ត្រូវលាឈប់ពីមុខតំណែង។

**៧.១១.**កែប្រព័ន្ធបោះឆ្នោតឲ្យទៅជា ប្រព័ន្ធឯកត្តនាម ឬប្រព័ន្ធចម្រុះ ដោយឲ្យមានបេក្ខជនឯករាជ្យអាចឈរឈ្មោះបាន។ ប្រជាពលរដ្ឋជាអ្នកបោះឆ្នោតដោយផ្ទាល់ ជ្រើសរើស ប្រធានភូមិ មេឃុំ/ចៅសង្កាត់ អភិបាលស្រុក/ខណ្ឌ/ក្រុង និងអភិបាលរាជធានី/ខេត្ត។ ជំរុញឲ្យមានតំណាងពលរដ្ឋជាជនជាតិដើមភាគតិចនៅក្នុងក្រុមប្រឹក្សាមូលដ្ឋាន និងនៅក្នុងសភាជាតិ។

**៧.១២.**កែទម្រង់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដោយមិនត្រូវជ្រើសចេញពីគណបក្ស

នយោបាយឡើយ តែត្រូវជ្រើសចេញពីមជ្ឈដ្ឋានឯករាជ្យ ដើម្បីធានាអព្យាក្រឹតភាព នៃស្ថាប័នបោះឆ្នោតនេះ ក្នុងការរៀបចំការបោះឆ្នោត ប្រកបដោយ សេរី ស្មើភាព ត្រឹមត្រូវ និងយុត្តិធម៌ ពិតប្រាកដ។

**៧.១៣.**រៀបចំចំនួនសមាជិកគណៈរដ្ឋមន្ត្រី គណៈអភិបាលគ្រប់លំដាប់ថ្នាក់ និងទីប្រឹក្សាឲ្យមានចំនួនតិចតែបំពេញការងារជាប្រយោជន៍ជាតិមានប្រសិទ្ធភាព។

**៧.១៤.**បង្កើតអង្គភាពឯករាជ្យថ្នាក់ជាតិផ្នែកសិទ្ធិមនុស្ស ដើម្បីប្រឆាំងទប់ស្កាត់ការរំលោភសិទ្ធិមនុស្សឲ្យមានប្រសិទ្ធភាព។

**៧.១៥.**ធ្វើវិសោធនកម្មច្បាប់ ប្រឆាំងអំពើពុករលួយឲ្យស្របតាមស្តង់ដារអន្តរជាតិ ដោយផ្តល់ឯករាជ្យភាពដល់អង្គភាពប្រឆាំងអំពើពុករលួយ តាមរយៈការផ្តល់អំណាចសម្រេច និងថវិកាសម្រាប់អនុវត្តគ្រប់

គ្រាន់ ដើម្បីអនុវត្តច្បាប់នេះឲ្យមានប្រសិទ្ធភាព ជាមួយវិធានការបោសសម្អាតអំពើពុករលួយពីលើចុះក្រោម (ពីអ្នកធំមកតូច) និងតម្រូវឲ្យអ្នកដឹកនាំប្រកាសទ្រព្យសម្បត្តិខ្លួន និងគ្រួសារ ជាសាធារណៈ ជាមុន និងក្រោយកាន់តំណែង។

**៧.១៦.**បង្កើនប្រសិទ្ធភាពសេវាសាធារណៈ ដោយផ្តល់ជូនមន្ត្រីរាជការ គ្រូបង្រៀន និងកង កម្លាំងប្រដាប់អាវុធ ឲ្យទទួលបានប្រាក់បៀវត្សសមរម្យអាចរស់នៅដោយថ្លៃថ្នូរបាន ព្រមទាំងផ្តល់ មុខងារ និងតួនាទី យោងតាមសមត្ថភាព និងគុណសម្បត្តិការងារ។ រាល់ការជ្រើសរើសមន្ត្រីបុគ្គលិកបម្រើការងាររដ្ឋ ឬការតម្លើងឋានន្តរស័ក្តិ ត្រូវធ្វើឡើងតាមវិធានការរដ្ឋបាលត្រឹមត្រូវ តាមរយៈការប្រឡងប្រជែងដោយតម្លាភាព

ឬតាមចំណេះ បទពិសោធន៍ និងសមត្ថភាព ដោយគ្មានការសូកប៉ាន់ និងគ្រួសារបក្ខពួក។

**៧.១៧.**កែទម្រង់ប្រព័ន្ធយុត្តិធម៌ ឲ្យធានាបានការផ្តល់សេវាយុត្តិធម៌ត្រឹមត្រូវ ដោយគោរពនូវ ឯករាជ្យភាពនៃប្រព័ន្ធតុលាការ អនុវត្តឲ្យមានប្រសិទ្ធភាពក្នុងកិច្ចការត្រួតពិនិត្យ និងដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញា ដែលប្រព្រឹត្តខុស លើកកម្ពស់តុលាការមិនឲ្យស្ថិត នៅក្រោមអំណាចបុគ្គល អំណាចគណបក្សនយោបាយ ឬអំណាចនីតិប្រតិបត្តិឡើយ។ ទប់ស្កាត់អំពើពុករលួយចំពោះចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីតុលាការផ្សេងទៀតឲ្យមានប្រសិទ្ធភាព។ កែទម្រង់សមាសភាពឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីធានាការប្រព្រឹត្តទៅនៃសាលាជម្រះក្តីឲ្យប្រព្រឹត្តិទៅដោយតម្លាភាព និងធានាបានយុត្តិធម៌ត្រឹមត្រូវ។

**៧.១៨.**ការពារជាដាច់ខាតនូវបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជានិងមិនទទួលស្គាល់ ព្រំដែនឬសន្ធិសញ្ញាណាដែលធ្វើឲ្យបាត់បង់ទឹកដីជាដាច់ខាត។

**៧.១៩.**ចាត់វិធានការបង្ការ និងការពារព្រំដែនដោយសន្តិវិធី តាមរយៈ ការអភិវឌ្ឍតាមបណ្តោយព្រំដែន មានការសាងសង់ ផ្លូវថ្នល់ ស្ពាន មន្ទីរពេទ្យ សាលារៀន វត្តអារាម និងផ្សារជាដើម ដើម្បីលើកទឹកចិត្តឲ្យប្រជាពលរដ្ឋខ្មែរទូទៅរស់នៅតាមព្រំដែនឲ្យបានកាន់តែច្រើន។

**៧.២០.**ចាត់វិធានការឲ្យទាន់ពេល តាមផ្លូវច្បាប់ដោយអហិង្សា និងម៉ឺងម៉ាត់ ចំពោះជនអន្តោប្រវេសន៍ដែលមករស់នៅខុសច្បាប់តាមរយៈការអនុវត្តច្បាប់សញ្ជាតិ និងច្បាប់អន្តោប្រវេសន៍ឲ្យបានត្រឹមត្រូវ និង

ផ្តន្ទាទោសចំពោះមន្ត្រីមានសមត្ថកិច្ចណាដែលប្រព្រឹត្ត ផ្ទុយពីច្បាប់ និងការទទួលខុសត្រូវរបស់ខ្លួន។

**៧.២១.** លុបចោលជាបន្ទាន់ នូវការផ្តល់ដីសម្បទានដល់ក្រុមហ៊ុនមកពីប្រទេសជិតខាង ឬរដ្ឋបរទេស ដែលយកពលរដ្ឋគេ ឲ្យមករស់នៅបម្រើការងារក្នុងតំបន់ដីសម្បទាន។

**៧.២២.**ពង្រឹង និងពង្រីក កិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ ជាមួយរដ្ឋាភិបាលប្រទេសនានាក្នុងពិភពលោក ដោយឈរលើស្មារតីគោរពអធិបតេយ្យគ្នាទៅវិញទៅមក។

**៧.២៣.**ប្រើប្រាស់កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ដើម្បីឲ្យប្រទេសជាហត្ថលេខី បន្តជួយធានាការពារដល់ បូរណភាពទឹក

ដី អធិបតេយ្យភាព និងឯករាជ្យភាព នៃព្រះរាជាណាចក្រកម្ពុជា។

## ៨-ផ្នែកលើកស្ទួយស្ត្រី

### ចក្ខុវិស័យ

*ស្ត្រីមានតួនាទីយ៉ាងសំខាន់ ក្នុងការសង្គ្រោះសេចក្តីថ្លៃថ្នូរ និងសុខុមាលភាពក្នុងសង្គមជាតិ តាមរយៈភាពអត់ធ្មត់ ភាពមានការទទួលខុសត្រូវ និងភាពហ្មត់ចត់ក្នុងការងារ ដែលស្ត្រីមានជាធម្មជាតិ។ ដូច្នេះ **គណបក្សភ្លើងទៀន** មានការប្តេជ្ញាច្បាស់លាស់ ដើម្បីការពារ និងជំរុញស្ត្រីឲ្យទទួលបានជោគជ័យក្នុងការចូលរួមកិច្ចការសង្គម និង នយោបាយ។*

រាជរដ្ឋាភិបាល**គណបក្ស ភ្លើងទៀន** មានទិសដៅក្នុងកិច្ចការពារ និងលើកស្ទួយស្ត្រីខ្មែរ ដូចតទៅ ៖

**៨.១.ផ្ដល់**ការជួយឧបត្ថម្ភ និងការលើកទឹកចិត្តពិសេសដល់ស្ត្រីក្នុងការអាចទទួលបានការអប់រំដល់គ្រប់កម្រិត។

**៨.២.**បែងចែកតំណែងនិងតួនាទីក្នុងការងាររដ្ឋនិងនយោបាយដល់ស្ត្រីឲ្យមានតុល្យភាពនឹងចំនួនបុរស។

**៨.៣.**កំណត់ក្នុងច្បាប់ ការពារកុំឲ្យមានការរើសអើងចំពោះស្ត្រីក្នុងវិស័យការងារ មុខតំណែង និងប្រាក់ខែ។

**៨.៤.**ជួយស្ត្រីឲ្យទទួលបានសេវាដោយឥតបង់ប្រាក់ក្នុងការបង្កើតកូន និងការថែរទាំទារក។

**៨.៥.**ធានា និងការពារស្ត្រីជាជនជាតិដើមក្នុងការប្រើប្រាស់ដីសហគមន៍ និងគ្រប់គ្រងដីតាមបែបជាប្រពៃណីរបស់ខ្លួន។

៨.៦.ធានាឲ្យមានការចូលរួមពីស្ត្រី ក្នុងការធ្វើ សេចក្ដីសម្រេចទាំងឡាយ។

## ៩-ការប្រមូលថវិកាជាតិ និងការចំណាយ

ចំពោះថវិកា ដែលរាជរដ្ឋាភិបាលដឹកនាំដោយ **គណបក្ស ភ្លើងទៀន** ត្រូវការសម្រាប់ការអនុវត្តសារនយោបាយទាំង ៥ ចំណុច គឺគណបក្សនឹងប្រមូលថវិកាបន្ថែម ពីចំណូលចរន្តរបស់ជាតិបច្ចុប្បន្ន និងការកាត់បន្ថយការចំណាយខ្ជីខ្ជាពីគំរោងមិនចាំចាច់នានា និងការបំប៉ោងការចំណាយគ្មានតម្លាភាព ដែលកើតមានតាមក្រសួងមន្ទីរ និងស្ថាប័នជាតិមួយចំនួន។

**ក-ការប្រមូលថវិកាបន្ថែម៖**

១.បង្កើនប្រសិទ្ធភាពការប្រមូលពន្ធដារ និងពន្ធគយតាមច្បាប់កំណត់ ដោយប្រើប្រព័ន្ធបច្ចេកទេស

ទំនើប មិនអនុញ្ញាតឲ្យមានការបន្លំពន្ធ ឬការគេចពន្ធ តាមរយៈឥទ្ធិពលអ្នកមានអំណាច និងអំពើពុករលួយឡើយ។

**២.**ចំណូលពីការបង្កើននូវប្រសិទ្ធភាព នៃការប្រមូលពន្ធពីវិស័យទេសចរណ៍ និងប្រាក់ចំណូលពីការលក់សំបុត្រទស្សនាប្រាសាទបុរាណ។

**៣.**ចំណូលពីការយកឈ្នួល លើដីសម្បទានទាំងឡាយ ក្នុងតម្លៃយ៉ាងតិច ១០០ដុល្លារមួយហិកតាក្នុងមួយឆ្នាំ ព្រមទាំងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដែលលក់ និងជួលផ្សេងទៀត។

**៤.**ចំណូលពីការផ្តល់អាជ្ញាប័ណ្ណ និងការធ្វើអាជីវកម្មរ៉ែផ្សេងៗ មានថ្ម និងខ្សាច់ ពិសេសចំណូលពីរ៉ែមាស រ៉ែដែក ត្បូងថ្ម ប្រេងកាត និងឧស្ម័ន។

៥.ធ្វើច្បាប់គ្រប់គ្រងបនល្បែងកាស៊ីណូ និងល្បែងអនឡាញ(Game Online) ដោយមានការកំណត់ពន្ធឲ្យបានត្រឹមត្រូវ។

៦.ចំណូលពីការធ្វើ និងផ្ទេរកម្មសិទ្ធិដីធ្លី និងលក់អចលនទ្រព្យរដ្ឋ។

៧.ចំណូលពីសេវាផ្តល់ទិដ្ឋាការ និងលិខិតឆ្លងដែន។

**ខ-ការទប់ស្កាត់ការបំប៉ោងចំណាយ និងការចំណាយខ្ជះខ្ជាយ៖**

១.កាត់បន្ថយនូវការចំណាយអត់ប្រយោជន៍ ដូចជាការចំណាយលើបុគ្គលិករាជការ កងកម្លាំងប្រដាប់អាវុធ មានតែឈ្មោះអត់មនុស្ស ឬមានឈ្មោះបម្រើការងាររដ្ឋច្រើនកន្លែង។

**២**.ការចំណាយលើទីប្រឹក្សា ជំនួយការ ក្រុមអង្គរក្សដ៏ច្រើន ការចំណាយលើ ចំនួនសមាជិក រដ្ឋាភិបាល និងអភិបាលរងរាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌដ៏ច្រើនសន្ធឹកសន្ធាប់។ល។ បំបាត់ការបំប៉ោងចំណាយលើការសាងសង់ និងទិញសម្ភារៈសម្រាប់រដ្ឋ ដោយគ្មានការដេញថ្លៃ និងត្រួតពិនិត្យត្រឹមត្រូវ៕

# ដើម្បីខ្មែរទាំងអស់គ្នា!



## ពុំមានសន្តិភាព បើគ្មានយុត្តិធម៌

**NO PEACE WITHOUT JUSTICE**